ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ
វាយតំលៃនិងប្រគល់កិច្ចសន្យា គបវប (PEAC)
លេខ : 254 PEAC. អក

រាជធានីភ្នំពេញ , ថ្ងៃទី 26 ខែ មីនា ឆ្នាំ 2014

# សេចក្តីជូនដំណឹងលើកទី ២

## ស្តីពី

## ការដេញថ្លៃផ្គត់ផ្គង់សំភារៈនិងពលកម្មតម្លើងប្រព័ន្ធបណ្តាញតង់ស្យុងទាប ចំនួន 07 តំបន់ នៅអគ្គិសនីកំពង់ចាម

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុនផ្គត់ផ្គង់សំភារៈនិងតំលើងប្រព័ន្ធបណ្តាញអគ្គិសនី ក្នុងស្រុក ( គិតទាំងសហគ្រាសឯកត្តបុគ្គល )និងក្រុមហ៊ុនបរទេសទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា : អគ្គិសនីកម្ពុជានឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់សំភារៈនិងពលកម្មតម្លើងប្រព័ន្ធបណ្តាញតង់ស្យុងទាបចំនួន 07 តំបន់ នៅអគ្គិសនីកំពង់ចាម ។

អគ្គិសនីកម្ពុជាបានរៀបចំឯកសារសំរាប់ក្រុមហ៊ុនបំពេញ ដើម្បីចូលរួមដេញថ្លៃ និង មានដាក់លក់នៅអង្គភាពលទ្ធកម្ម អាស័យដ្ឋាន ផ្លូវព្រះយុគន្ធរ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ ចាប់ពី *ថ្ងៃទី 27 ខែ មីនា ឆ្នាំ2014* តទៅរៀងរាល់ម៉ោងធ្វើការ ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មយ៉ាងយូរបំផុតត្រឹម *ថ្ងៃទី 03 ខែ មេសា ឆ្នាំ 2014* វេលា *ម៉ោង 14:00* គត់ ។

ការបើកឯកសារដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មតាមអាស័យដ្ឋានខាងលើ វេលា *ម៉ោង 15:30 ថ្ងៃទី 03 ខែមេសា ឆ្នាំ 2014* ។

ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬ មានប្រភពតែមួយ អាចដាក់ឯកសារដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុនដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មអគ្គិសនីកម្ពុជា ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័តមានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

សូមទាក់ទង
ទូរស័ព្ទលេខ : 023 67 66 007
Website : www.edc.com.kh

ចំលងជូន :
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
" អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ "
- ឯកសារ-កាលប្បវត្តិ

ELECTRICITE DU CAMBODGE